# ក្រុមហ៊ុន ភ្នំពេញ ស្ករអំពៅ

# PHNOM PENH SUGAR Co., Ltd.

អាសយដ្ឋាន : សណ្ឋាគារភ្នំពេញ លេខ ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

លេខ: ០០៤/ក.ស
/២០០៧

**សូមគោរពជូន**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។

**កម្មវត្ថុ** : សំណើសុំគោលការណ៍វិនិយោគដីសម្បទានចំនួន ១០.០០០ ហិកតា ស្ថិតនៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ សំរាប់វិនិយោគដាំអំពៅស្ករ ដាំឈើផ្សេងៗ និងបង្កើតរោងចក្រផលិតស្ករ ។

**ជូនភ្ជាប់** :-ផែនទី ទីតាំងដីស្នើសុំសម្បទាន ចំនួន ០១ ច្បាប់

- សំណើរបស់ក្រុមហ៊ុនលេខ ០០១/២០០៩ ក.ស ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកភាពដោយអភិបាលខេត្តកំពង់ស្ពឺលេខ ៥៧១ សរសណ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩ ចំនួន ០១ ច្បាប់ ។
- លិខិតរបស់ក្រសួងបរិស្ថានលេខ ៤៥៣ សជណ.បស្ថ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩ ចំនួន ០១ ច្បាប់ ។
- របាយការណ៍ EIA ចុះខែ សីហា ឆ្នាំ ២០០៩

សេចក្តីដូចបានគោរពជំរាបជូនក្នុងកម្មវត្ថុ និងឯកសារជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី មេត្តាជ្រាប ថា : ក្រុមហ៊ុនយើងខ្ញុំមានបំណងពិតប្រាកដក្នុងការវិនិយោគលើដំណាំកសិឧស្សាហកម្ម : ដំណាំអំពៅ ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍តំបន់ដាច់ស្រយាល ដើម្បីរួមចំណែកកសាងសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ ដោះស្រាយការងារជូនប្រជាពលរដ្ឋនៅតំបន់នោះមានការងារធ្វើ អោយមានជីវភាពកាន់តែធូរធាថែមទៀត ព្រមទាំងបង្កើតរោងចក្រផលិតស្ករស និងរោងចក្រកែច្នៃផ្សេងៗ តាមលក្ខណៈជាក់ស្តែង ។ ដូច្នេះហើយក្រុមហ៊ុនយើងខ្ញុំបានចុះសិក្សាតំរោងមួយកន្លែងស្ថិតនៅក្នុងឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដោយមានការសហការល្អជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ពីថ្នាក់ភូមិ រហូតដល់ថ្នាក់ខេត្ត និង បានប្រជុំជាមួយប្រជាពលរដ្ឋផង ដោយមានការគាំទ្រពីប្រជាពលរដ្ឋនៅតំបន់នោះ លើគំរោងរបស់ក្រុមហ៊ុនថែមទៀត ។ ម្យ៉ាងទៀត ក្រុមហ៊ុនយើងខ្ញុំសន្យាថា ក្រោយពីបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាល ក្រុមហ៊ុនយើងខ្ញុំនឹងរៀបចំដំណើរការអនុវត្តន៍ឱ្យបានទាន់ពេលវេលា ។

អាស្រ័យហេតុដូចបានគោរពជំរាបជូនខាងលើ សូមសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និងសំរេចអនុញ្ញាតជាគោលការណ៍ឱ្យក្រុមហ៊ុនយើងខ្ញុំបានវិនិយោគលើដីសម្បទានដើម្បីកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ដោយក្តីអនុគ្រោះ ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩

នាយកក្រុមហ៊ុន

23-1-07

ឧកញ៉ា លី យ៉ុងផាត់

# ក្រុមហ៊ុន កំពង់ស្ពឺ ស៊ូហ្គើរ

## KAMPONG SPEU SUGAR Co., Ltd.

អាសយដ្ឋាន : សណ្ឋាគារភ្នំពេញ លេខ ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

---

លេខៈ ០០៧ ក.ស. / ២០០៩

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

**កម្មវត្ថុ** : សំណើសុំគោលការណ៍វិនិយោគដីសម្បទានចំនួន ១០.០០០ ហិកតា ស្ថិតនៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សំរាប់វិនិយោគដាំអំពៅស្ករ ដាំឈើផ្សេងៗ និងបង្កើតរោងចក្រផលិតស្ករ ។

**ជូនភ្ជាប់** :
- ផែនទី ទីតាំងដីស្នើសុំសម្បទាន ចំនួន ០១ ច្បាប់
- សំណើរបស់ក្រុមហ៊ុន លេខ ០០១/២០០៩ ក.ស ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកភាពដោយអភិបាលខេត្តកំពង់ស្ពឺលេខ ៥៦៩ សរសណ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩ ចំនួន ០១ ច្បាប់ ។
- លិខិតរបស់ក្រសួងបរិស្ថានលេខ ៤៥៤ សជណ.បស្ថ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩ ចំនួន ០១ ច្បាប់ ។
- របាយការណ៍ EIA ចុះខែ សីហា ឆ្នាំ ២០០៩

សេចក្តីដូចបានគោរពជំរាបជូនក្នុងកម្មវត្ថុ និងឯកសារជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី មេត្តាជ្រាប ថា : ក្រុមហ៊ុនយើងខ្ញុំមានបំណងពិតប្រាកដក្នុងការវិនិយោគលើដំណាំកសិឧស្សាហកម្ម : ដំណាំអំពៅ ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍តំបន់ដាច់ស្រយាល ដើម្បីរួមចំណែកកសាងសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ ដោះស្រាយការងារជូនប្រជាពលរដ្ឋនៅតំបន់នោះមានការងារធ្វើ អោយមានជីវភាពកាន់តែធូរធាថែមទៀត ព្រមទាំងបង្កើតរោងចក្រផលិតស្ករស និងរោងចក្រកែច្នៃផ្សេងៗ តាមលក្ខណៈជាក់ស្តែង។ ដូច្នេះហើយក្រុមហ៊ុនយើងខ្ញុំបានចុះសិក្សាគំរោងមួយកន្លែងស្ថិតនៅក្នុងឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដោយមានការសហការល្អជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ពីថ្នាក់ភូមិ រហូតដល់ថ្នាក់ខេត្ត និង បានប្រជុំជាមួយប្រជាពលរដ្ឋផង ដោយមានការគាំទ្រពីប្រជាពលរដ្ឋនៅតំបន់នោះ លើគំរោងរបស់ក្រុមហ៊ុនថែមទៀត ។ម្យ៉ាងទៀត ក្រុមហ៊ុនយើងខ្ញុំសន្យាថា ក្រោយពីបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាល ក្រុមហ៊ុនយើងខ្ញុំនឹងរៀបចំដំណើរការអនុវត្តន៍ឱ្យបានទាន់ពេលវេលា ។

អាស្រ័យហេតុដូចបានគោរពជំរាបជូនខាងលើ សូមសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និងសំរេចអនុញ្ញាតជាគោលការណ៍ឱ្យក្រុមហ៊ុនយើងខ្ញុំបានវិនិយោគលើដីសម្បទានដើម្បីកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ដោយក្តីអនុគ្រោះ ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩

នាយកក្រុមហ៊ុន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ: ១៧៤ ភសក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជំរាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**កម្មវត្ថុ** : ករណីសំណើសុំសម្បទានដីសេដ្ឋកិច្ចចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន ~~កំពង់ស្ពឺ~~ ភ្នំពេញ ស៊ូហ្គើរ (KAMPONG SPEU SUGAR Co.,Ltd) សម្រាប់វិនិយោគដាំដំណាំអំពៅ និងបង្កើតរោងចក្រធ្វើស្ករស ដែលមានទីតាំងស្ថិតនៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

**យោង** :_លិខិតលេខ ៦៦១/០៩១ កសក.នផ.ផក ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

_ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា ចំពោះករណីនេះ រាជរដ្ឋាភិបាលបានសំរេចដូចខាងក្រោម ៖

១_យល់ព្រមផ្តល់សម្បទានដីសេដ្ឋកិច្ចចំនួន ៩.០៥២ ហិកតា ជូនក្រុមហ៊ុន កំពង់ស្ពឺ ស៊ូហ្គើរ (KAMPONG SPEU SUGAR Co.,Ltd) សម្រាប់ធ្វើការវិនិយោគដាំដំណាំអំពៅ និងបង្កើតរោងចក្រធ្វើស្ករស ដែលមានទីតាំងស្ថិតនៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ សម្រាប់វិនិយោគតាមរូបភាពសម្បទានដីសេដ្ឋកិច្ច ។

២_បន្ទាប់ពីបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលរួចហើយ ក្រុមហ៊ុនត្រូវសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអាជ្ញាធរមានសមត្ថកិច្ច ចុះសិក្សាលំអិត និងចុះពិនិត្យកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ ផ្ទៃដីព្រៃឈើក្រាស់ៗ ដែលត្រូវរក្សាទុកបន្ថែមទៀត ដើម្បីជៀសវាងការប៉ះពាល់ផ្ទៃដីប្រើប្រាស់របស់ប្រជាពលរដ្ឋ និងតំបន់ការពារផ្សេងៗ ។

៣_ក្រុមហ៊ុនត្រូវធ្វើការចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋ និងចុះកិច្ចសន្យាធ្វើវិនិយោគសម្បទានដីសេដ្ឋកិច្ច ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៤_ចំពោះផ្ទៃដីព្រៃការពារប្រភពទឹក ព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង និងព្រៃល្បោះ ដែលត្រូវរក្សាទុកក្រោយពីការកាត់ទុក ក្រុមហ៊ុនត្រូវទទួលថែរក្សាការពារមិនឱ្យខូចខាតបាត់បង់ ដោយត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងត្រូវត្រួតពិនិត្យដោយរដ្ឋបាលព្រៃឈើ ។ ក្នុងករណីព្រៃឈើត្រូវបានបាត់បង់ ខូចខាត នោះរាជរដ្ឋាភិបាល នឹងលុបគោលការណ៍ និងកិច្ចសន្យាចោលភ្លាម ។

៥_ក្រុមហ៊ុនត្រូវគោរពនូវលក្ខខណ្ឌ ដោយធានាឱ្យប្រជាជននៅក្នុងតំបន់វិនិយោគ អាចទទួលបាននូវផលប្រយោជន៍ពីគម្រោងវិនិយោគ និងលក្ខខណ្ឌនៃការបង្កកគម្រោងវិនិយោគនៅតាមទីតាំងណា ដែលមានទំនាស់អំពីកម្មសិទ្ធិជាមួយប្រជាជន រហូតដល់មានការដោះស្រាយរួចរាល់ត្រឹមត្រូវ ។

៦_មុននឹងដំណើរការឈូសឆាយធ្វើអាជីវកម្ម ក្រុមហ៊ុនត្រូវធ្វើផែនការគ្រប់គ្រង និងអភិវឌ្ឍឱ្យបានច្បាស់លាស់ ធ្វើរបាយការណ៍ស្ដីពី ផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) ដោយមានការទទួលស្គាល់ពីស្ថាប័នជំនាញ មានការចូលរួមគាំទ្រពីអាជ្ញាធរ និងប្រជាពលរដ្ឋនៅមូលដ្ឋាន ។

៧_មុនការចាប់ផ្ដើមឈូសឆាយរានដីសម្រាប់អភិវឌ្ឍន៍ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ ចំពោះសំណល់ឈើដែលបានពីការឈូសឆាយក្នុងតំបន់សម្បទាន ក្រុមហ៊ុនត្រូវប្រមូលទុកឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសដែលកំណត់ដោយរដ្ឋបាលព្រៃឈើ ហើយនឹងត្រូវបង់សួយសារ និងបុព្វលាភជូនរដ្ឋអនុលោមតាមនីតិវិធីច្បាប់ស្ដីពីព្រៃឈើ ។

៨_ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ បើសិនជាក្រុមហ៊ុនមិនមានសកម្មភាពតាមការណែនាំរបស់រាជរដ្ឋាភិបាលទេ សុពលភាពនៃការផ្ដល់គោលការណ៍នឹងត្រូវផុតកំណត់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និង ណែនាំថែងអនុវត្តតាមការគួរ ។

ជ.នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ... ទីស្ដីការគណៈរដ្ឋមន្ត្រី

ប៊ិន_ឈិន

ចម្លងជូន
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ស្ពឺ
- អគ្គលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច
- រដ្ឋបាលព្រៃឈើ
- ក្រុមហ៊ុន កំពង់ស្ពឺ ស៊ូហ្គើរ (KAMPONG SPEU SUGAR Co.,Ltd)
- ឯកសារ-កាលប្បវត្តិ